ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ចន្ទ ៦ រោច ខែ មាឃ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២*
*រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៩*

# សេចក្តីប្រកាសព័ត៌មានស្តីពីកម្មវិធី

## “ប្រកាសដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជាផ្លូវការ”

## នៅក្រសួង-ស្ថាប័ន ចំនួន ១០ និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី-ខេត្ត ទាំង ២៥ និង ប្រកាសពង្រីកការអនុវត្តគម្រោង FMIS ទៅកាន់ក្រសួង-ស្ថាប័នចំនួន ១៧ ផ្សេងទៀតសម្រាប់ឆ្នាំ ២០១៩

នាព្រឹកថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានរៀបចំកម្មវិធី “**ប្រកាសដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** (Financial Management Information System “FMIS”) **ជាផ្លូវការ**” នៅក្រសួង-ស្ថាប័ន ចំនួន ១០ និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី-ខេត្តទាំង ២៥ និងប្រកាសពង្រីកការអនុវត្តគម្រោង FMIS ទៅកាន់ក្រសួង-ស្ថាប័នចំនួន ១៧ ផ្សេងទៀតសម្រាប់ឆ្នាំ ២០១៩, ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី** ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដោយមានការចូលរួម ពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, តំណាងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្តទាំង ២៥ តំណាងក្រសួង-ស្ថាប័ន សរុបប្រមាណ ២៣០ រូប ។

ដោយប្រកាន់ខ្ជាប់នូវចក្ខុវិស័យច្បាស់លាស់ និង ប្រាកដប្រជា, កម្ពុជា បាន និងកំពុងប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលផ្តោតលើធាតុចូល និងមជ្ឈការ ទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល និង វិមជ្ឈការស្របតាមស្តង់ដារអន្តរជាតិ ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានបញ្ជាក់ថា វឌ្ឍនភាពដ៏ធំធេងនៃការអនុវត្តគម្រោង FMIS តាំងពីឆ្នាំ ២០១៤ រហូតមកដល់ពេលនេះ គឺជាជាឆ្អឹងខ្នង និង បានរួមចំណែកយ៉ាងខ្លាំង ក្នុងការជំរុញឱ្យកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានបោះជំហានទៅមុខជាមួយនឹងការចាក់គ្រឹះដ៏រឹងមាំសម្រាប់ឈានទៅសម្រេចគោលដៅនៅឆ្នាំ ២០២៥ គឺ “***គណនេយ្យភាពសមិទ្ធកម្ម***” ។ នេះគឺជាមោទនភាព សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ព្រោះថាយើងធ្វើបានល្អប្រសើរ និង បានលឿនជាងបណ្តាប្រទេសមួយចំនួនទៀត បើយោងតាមការវាយតម្លៃរបស់ធនាគារពិភពលោក ។ “***វឌ្ឍនភាព និងសមិទ្ធផល***” នេះ គឺបានកើតចេញពីការខិតខំប្រឹងប្រែងរបស់យើងទាំងអស់គ្នា ដោយឈរលើមូលដ្ឋាន ***ប្រមូលផ្តុំ, ពិភាក្សា និង ដោះស្រាយរួមគ្នា ក្នុងស្មារតីជាក្រុមតែមួយ***” ។

នៅឆ្នាំ ២០១៩ នេះ, ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានដាក់ចេញនូវផែនការសកម្មភាពសម្រួលនីតិវិធីអនុវត្តការងារ ក្នុងប្រព័ន្ធ FMIS ដែលកំណត់ឱ្យបានច្បាស់អំពីនីតិវិធីដើម្បីឱ្យការអនុវត្តន៍មានអនុលោមភាពទៅនឹង “***យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥***”។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានផ្ដាំផ្ញើរដល់ក្រសួង-ស្ថាប័ន ដែលនឹងប្រើប្រាស់ប្រព័ន្ធ FMIS ក្នុងឆ្នាំ ២០១៩÷

១. ថ្នាក់ដឹកនាំ និង មន្ត្រីអនុវត្តការងារថវិកា និងហិរញ្ញវត្ថុ ត្រូវចូលរួមអនុវត្តប្រកបដោយស្មារតីបុរេសកម្ម និង អន្តរសកម្ម រួមជាមួយនឹងឆន្ទៈខ្ពស់, ការភ្ញាក់រលឹក និងមានភាពម្ចាស់ការ ពិសេស ពីថ្នាក់ដឹកនាំ និង សមាជិកនៃក្រុមការងារអនុវត្តគម្រោង FMIS ប្រចាំក្រសួង-ស្ថាប័ន,

២. ត្រៀមលក្ខណៈសម្រិតសម្រាំងមន្ត្រីដែលត្រូវប្រើប្រាស់ប្រព័ន្ធ FMIS ឱ្យត្រូវតាមតម្រូវការ និងជំនាញវិជ្ជាជីវៈ ចៀសវាងយកមន្ត្រីដែលពុំមានការពាក់ព័ន្ធ ឬ ខុសមុខងារ ក៏ដូចជា ជំរុញនិងលើកទឹកចិត្តដល់មន្ត្រីក្រោមឱវាទក្នុងការចូលរួមវគ្គបណ្ដុះបណ្ដាលនានា ដែលរៀបចំឡើងក្នុងក្របខណ្ឌ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេស ក្នុងគម្រោង FMIS,

៣. ត្រូវគិតគូរ, វិភាគ និងកំណត់ឱ្យបានច្បាស់អំពីចំនួនថ្នាក់ដឹកនាំ និងមន្ត្រីដែលត្រូវចាត់តាំងជាអ្នកប្រើប្រាស់ប្រព័ន្ធ FMIS ដើម្បីបង្ការនូវការស្នើសុំបន្ថែម និង ផ្លាស់ប្ដូរអ្នកប្រើប្រាស់ប្រព័ន្ធ ដែលអាចបង្កភាពស្មុគស្មាញ ទាំងការរៀបចំវគ្គបណ្ដុះបណ្ដាល និងនៅពេលប្រើប្រាស់ប្រព័ន្ធ,

៤. ត្រូវពិនិត្យលើមូលដ្ឋានច្បាប់ និង បទដ្ឋានគតិយុត្តចាំបាច់នានា ដែលត្រូវត្រៀមរៀបចំកែលម្អ សម្រាប់ទ្រទ្រង់ដល់ការប្រើប្រាស់ប្រព័ន្ធ FMIS ប្រកបដោយប្រសិទ្ធភាពខ្ពស់ ពិសេស ការកាត់សម្រួលនីតិវិធីអនុវត្តការងារនៅក្នុងស្ថាប័នរបស់ខ្លួន ដើម្បីកាត់បន្ថយនូវភាពស្មុគស្មាញ ដែលអាចកើតមាននៅពេលដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS និង

៥. ត្រូវត្រៀមរៀបចំកន្លែងការងារ និងក្រុមការងារអនុវត្តគម្រោង FMIS របស់ខ្លួន ដើម្បីចូលរួមសហការធ្វើការងារឱ្យបានជិតស្និទ្ធ ជាមួយក្រុមការងារគ្រប់គ្រង FMIS របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ធ្វើការរួមគ្នាជាក្រុមតែមួយ ក្នុងការសម្រេចឱ្យបានជោគជ័យតាមការដ្ឋាននីមួយៗ និង តាមផែនការសកម្មភាពដែលបានដាក់ចេញ ។

សម្រាប់ដើមឆ្នាំ ២០១៩ នេះ ប្រព័ន្ធ FMIS នឹងត្រូវបន្តដាក់ឱ្យដំណើរការនូវមុខងារចំនួន ៤ ក្នុងចំណោមមុខងារស្នូលសំខាន់ទាំង ៦ របស់ប្រព័ន្ធ ក្នុងនោះរួមមាន÷ **១. មុខងារវិភាជន៍ថវិកា, ២. មុខងារទិញ និង គ្រប់គ្រងធានាចំណាយ, ៣. មុខងារគណនីត្រូវសង** និង **៤. មុខងារគណនីត្រូវទារ** ។ ក្រសួង-ស្ថាប័នចំនួន ១០ បន្ថែមទៀតដែលត្រូវដាក់ឱ្យដំណើរការ គឺ÷ ១. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ២. ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់, ៣. ក្រសួងពាណិជ្ជកម្ម, ៤. ក្រសួងសាធារណការ និងដឹកជញ្ជូន, ៥. ក្រសួងធនធានទឹក និងឧតុនិយម, ៦. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា, ៧. ក្រសួងអភិវឌ្ឍន៍ជនបទ, ៨. ក្រសួងព័ត៌មាន, ៩. ក្រសួងទេសចរណ៍ និង ១០. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រួមទាំង គ្រប់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី-ខេត្តទាំង ២៥ ។